# ប្រទេសកម្ពុជាសម័យចេនឡា

ចេនឡា គឺជាឈ្មោះអាណាចក្រមួយដែលកើតឡើង ក្រោយពី អាណាចក្រភ្នំបានដួលរលំ។ ក្រោយមកចេនឡា ក៏ត្រូវបានបែង ចែកជាពីរ គឺចេនឡាខាងជើងជាចេនឡាដីគោក និងចេនឡាខាងត្បូងជាចេនឡាទឹកលិច។

## ១.គ្រាដំបូងនៃចេនឡា (CHENLA)

### ក-បញ្ហាឈ្មោះ

កាលដើមឡើយចេនឡាជាសាមន្តរដ្ឋរបស់អាណាចក្រភ្នំ ក្រោយមកបានវាយយកអាណាចក្រនេះបញ្ចូលទៅជាចេនឡាធំ ហើយបានទទួលឋានៈជារដ្ឋអធិបតេយ្យមួយរហូតដល់ពាក់កណ្ដាលទី២ នៃសតវត្សរ៍ទី៨។

ចំពោះបញ្ហាឈ្មោះថាចេនឡា នេះមានអ្នកប្រវត្តិសាស្ត្រជាច្រើនបានហៅតាមចិន ហើយពុំបានដឹងថាវាមានន័យយ៉ាងណានោះទេ។ ចំពោះពាក្យចេនឡានេះអ្នកសិក្សាបានធ្វើការសិក្សាស្រាវជ្រាវ ហើយបានបញ្ចេញទស្សនៈដែលមានភាពប្លែកៗពីគ្នាទៅតាមការយល់ឃើញរបស់ពួកគេ។

**លោក ប៉ូល ប៉េលីយ៉ូត** ដែលបានធ្វើការសិក្សាអំពីប្រវត្តិសាស្ត្រ និងអរិយធម៌ខ្មែរបាននិយាយថា ពាក្យចេនឡាទំនងជាកើតឡើងដោយការផ្សំពាក្យ ចិន និងពាក្យ រាប កកើតបានទៅជាពាក្យថាចេនឡា ។ **លោក ប៉ូល ប៉េលីយ៉ូត** យល់ថាខ្មែរ ដែលមានព្រំប្រទល់នៅជាប់នឹងចិន ធ្លាប់មានជម្លោះនឹងគ្នាហើយខ្មែរ ធ្លាប់បានទទួលជោគជ័យលើចិន ក៏ហៅកន្លែងនោះថា **ចិនរាប** ចិនថាត្រាប់តាមខ្មែរពុំច្បាស់ ក៏ហៅថា **ចេនឡា** ទៅវិញ។

**លោក កេង វ៉ាន់សាក់** ដែលជាអ្នកស្រាវជ្រាវខាងអក្សរសាស្ត្រខ្មែរ លោកមានទស្សនៈថាពាក្យ ចេនឡា ក្លាយមកពីពាក្យ ចិន និង ពាក្យ លា(លាត្រឡប់ទៅវិញ) ដោយហេតុថាចិនមិនអាចត្រួតត្រា នៅកន្លែងដែលខ្មែររស់នៅទីនោះបាន ក៏ដកថយទៅវិញ ទើបមានឈ្មោះថា ចិនលា ដូច្នេះហើយពាក្យចិនលា ក៏ក្លាយទៅជាពាក្យ ចេនឡា ។ ដូច្នេះបានន័យថាប្រហែលជាចិនធ្លាប់មកត្រួតត្រាលើប្រទេសខ្មែរនាសម័យនោះ ឬយ៉ាងណា?

**លោក លី ធាមតេង** ដែលជាអ្នកសិក្សាខាងអក្សរសាស្រ្តដែរនោះ គាត់បាននិយាយថារូបលោកធ្លាប់បានជួបអ្នកស្រាវជ្រាវចិនម្នាក់ដែលអ្នកស្រាវជ្រាវចិននោះធ្លាប់បានឃើញឯកសារប្រវត្តិសាស្រ្តនិយាយពីឈ្មោះចេនឡា គឺជាពាក្យចិនហៅសំគាល់ប្រទេសមួយនៅភាគខាងលើនគរភ្នំ។ នគរភ្នំជាប្រទេសសម្បូរឃ្មុំយកទៅលក់នៅស្រុកចិនសម្រាប់ធ្វើជាទៀន។ពួកចិន តែងមកទិញដូរយកក្រមួនសុទ្ធពីឃ្មុំយកទៅលក់នៅស្រុកចិនសម្រាប់ធ្វើជាទៀន ចិនគេបានហៅថាជាស្រុកក្រមួនសុទ្ធ។ ដោយពាក្យចេនប្រែថាសុទ្ធ ឯឡា ឬឡាក់ប្រែ ថាក្រមួន។ ដោយភាសាចិនគេដាក់គុណនាមមុន ផ្សំពាក្យទៅ ហៅថាក្រមួនសុទ្ធដែលប្រែថា ចេនឡា។

ទស្សនៈលោកឆត្រាប្រេមឬឌីលោកថាប្រទេសខ្មែរកាលពីសម័យបុរាណផ្នែកខាងលើហៅថា ជាន់លើ ឯផ្នែកខាងក្រោមហៅ ថា ក្រោមពូជ ។ ពាក្យជាន់លើចិនហៅមិនច្បាស់ក៏ក្លាយជាចេនឡា ជាន់លើ > ចេនឡា ។

**លោក ពៅ ឈិនតាម** សៀវភៅអរិយធម៌ខ្មែរ-មនទំព័រ៣២-៣៣ លោកសរសេរថា....ហើយពុំទាន់មានស្តេចទេគឺ មានកុលសម្ព័ន្ធពីរគឺមន១និងខម១ប៉ុណ្ណោះឯង។ ថាកុលសម្ព័ន្ធមននៅតាមដងទន្លេមេណាមស្រុកសៀមរហូតដល់ភាគខាងត្បូង ភូមា ឯកុលសម្ព័ន្ធខមនៅចាប់ពីស្រុកបាភ្នំ-លពបុរី-ស្រីអយុធ្យា និងនៅលើដីកោះគោកធ្លកតាមជួរភ្នំដងរែករហូតទៅដល់ស្រុក ចិនទើបបានជាមានពាក្យថាចិនឡា។ មួយទៀតថាដោយហេតុតែដីកោះទាំងនោះមានមាសច្រើន ទើបបានជាមានពាក្យថា សុវណ្ណភូមិនោះឯង។

## ខ.ទីតាំងរបស់ចេនឡា

ទីតាំងរបស់អាណាចក្រចេនឡា តាមឯកសារចិនបានអោយដឹងថា នៅត្រង់តំបន់បាសាក់ តាមដងទន្លេមេគង្គដែលបច្ចុប្បន្ននៅភាគអាគ្នេយ៍ប្រទេសឡាវ ស្ថិតត្រង់មាត់ទន្លេមូន។ ស្តេចដំបូងនៃរដ្ឋចេនឡា ក៏ដូចជានគរភ្នំដែរបានធ្វើនយោបាយពង្រីកទឹកដីហើយការពង្រីកទឹកដីទៅភាគខាងជើង ទៅភាគខាងត្បូងទៅវាលទំនាបទន្លេមេគង្គ និងតំបន់ជុំវិញបឹងទន្លេសាប។ រជ្ជកាលស្តេចឦសានវរ្ម័ន ក៏មានការពង្រីកទៅដល់ភាគខាងកើតប្រទេស ថៃ

សព្វថ្ងៃ។

តាមការនិយាយរបស់ **ស៊ាន់ ឈ័ង** ថាទឹកដីនៃប្រទេសចេនឡា ត្រូវបានប្រមូលផ្តុំទៅដោយតំបន់នានាជុំវិញទីតាំងរបស់ខ្លួន ភវបុរៈ ហើយត្រូវបានបែងចែកភូមិសាស្ត្រធម្មជាតិជាពីរផ្នែកផ្សេងគ្នា។ តំបន់ភាគខាងជើង គឺជាតំបន់ដីខ្ពស់ មានចាប់ពីជួរភ្នំដងរែកទៅដល់ព្រំប្រទល់រដ្ឋ ណាននាវ (NAN CHAO) របស់ថៃនៅតំបន់យុនណាន់ (YUNNAN) ដែលសព្វថ្ងៃជាខេត្តមួយរបស់ចិនភាគខាងត្បូង។ តំបន់ភាគខាងជើងជាតំបន់សម្បូរទៅដោយជួរភ្នំ ជ្រលងភ្នំ និងខ្ពង់រាប។ តំបន់ភាគខាងត្បូង ឬតំបន់ទំនាបដែលស្ថិតនៅតាមវាលទំនាបនៃដងទន្លេមេគង្គនិងតំបន់ទន្លេសាប ជាតំបន់សម្បូរទៅដោយបឹងបួរទន្លេ និងមាត់សមុទ្រ។

## គ.ការបង្កើតអាណាចក្រចេនឡា

### គ.១-ការរើបំរះខ្លួនរបស់ចេនឡាពីអាណាចក្រភ្នំ

យើងបានឃើញរួចមកហើយថា ដំណើរវិវត្តនៃប្រវត្តិសាស្ត្រនៅក្នុងតំបន់នេះ គឺជាដំណើរវិវត្តនៃប្រជាជនខ្មែរដែលបានកើតឡើងនៅកន្លែងជាទីប្រសព្វរវាងទន្លេពីរ គឺទន្លេមេគង្គ និងទន្លេមូន ។ នៅចុងសម័យនៃរដ្ឋនគរភ្នំ ក៏កើតមានការដណ្តើមរាជ្យគ្នារវាង**ស្តេចគុណវរ្ម័ន និងរុទ្រវរ្ម័ន** ។ តាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្របានបង្ហាញនេះឲ្យដឹងថា ស្តេចរុទ្រវរ្ម័នបានបញ្ជូនរាជទូតទៅកាន់ប្រទេសចិនចុងក្រោយបង្អស់នៅ**ឆ្នាំ៥៣៩** ។ ប៉ុន្តែតាមប្រភពឯកសារចិនខ្លះបាននិយាយថា នគរភ្នំបានបញ្ជូនទូតទៅកាន់ប្រទេសចិន នាដើមសតវត្សរ៍ទី៧ នៅឡើយតែបានបញ្ជាក់ថារាជធានីនៃនគរភ្នំ វ្យាធបុរៈ ដែលចិនហៅថាតូម៉ូ (TOMO) ត្រូវបានបំផ្លាញខ្ទេចខ្ទី ហើយលើកផ្លាស់ទៅទិសខាងត្បូងដែលទីនោះគេហៅថាក្រុង នរវរនគរ នៅអង្គរបុរី ខេត្តតាកែវ ។

តាមសិលាចារឹកបក្សីចាំក្រុង (ស.វ.ទី១០) ស្តេចចេនឡាមានដើមកំណើតមកពីឥសីកម្ពុស្វយម្ភូវ និងនាងទេពអប្សរមេរា ដែលព្រះឥសូរប្រទានឲ្យធ្វើជាមហេសី ។ ស្តេចដំបូងមាន ព្រះនាមថាស្រុទ្ធវរ្ម័ន មានបុត្រមួយព្រះអង្គព្រះនាមថា ស្រេស្ថវរ្ម័ន ដែលបានកសាងទីក្រុងមួយហៅថា ក្រុង

ស្រេស្ថបុរៈ (SRESHTHAPURA)ទីក្រុងនេះទំនងស្ថិតនៅតំបន់បាសាក់ (វត្តភូ ប្រទេសឡាវសព្វថ្ងៃ) ។

នៅក្នុងរាជ្យ**ព្រះបាទ ស្រេស្ថវរ្ម័ន** នេះហើយក្នុងអំឡុង**ឆ្នាំ ៤៨៨** ដែលព្រះអង្គបានចាត់តាំងរាជទូតឲ្យនាំព្រះរាជសារ និងព្រះរាជបណ្ណាការទៅសុំចងសម្ព័ន្ធមិត្ត ជាមួយនឹងប្រទេសចិន ដែលនេះជាការបង្កើតទំនាក់ទំនងរវាងប្រទេសខ្មែរ និងប្រទេសចិនលើកទី៤។

តាមសិលាចារឹកបក្សីចាំក្រុងដដែល ក៏បាននិយាយថា ស្តេចនៅចេនឡាបានរំដោះអ្នកស្រុកឲ្យរួចចាកផុតពីអំណាចស្វយសាររអាករ និងខំរើបំរះខ្លួនឲ្យរួចផុតអំណាចគ្រប់គ្រងរបស់ស្តេចអាណាចក្រភ្នំ ។ នៅពាក់កណ្តាលទី២នៃសតវត្សរ៍ទី៦ ចេនឡា មានអានុភាពកាន់តែខ្លាំងឡើងៗ ហើយចាប់ផ្តើមធ្វើ
សង្គ្រាមវាយលុកប្រឆាំង និងដណ្តើមយកអាណាចក្រភ្នំមកត្រួតត្រាវិញម្តង ។ ស្តេចចេនឡា ដែលបានផ្តើមធ្វើសង្គ្រាមវាយលុកដណ្តើមអាណាចក្រភ្នំដំបូងមានព្រះនាមថា ភវវរ្ម័នទី១ (BHAVAVARMAN) ដែលត្រូវជាបុត្ររបស់ស្តេចវីរវរ្ម័ននិងត្រូវជាចៅរបស់ស្តេចរុទ្រវរ្ម័ន (RUDRAVARMAN) ។

**ស្តេចភវវរ្ម័នទី១** ជាស្តេចមានញាតិវង្សខាងអាណាចក្រភ្នំ (ហៅថា សោម វង្ស វង្សចន្ទ្រាឬព្រះច័ន្ទ) តែដោយព្រះអង្គបានរៀបអភិសេកជាមួយក្សត្រីយ កម្ពុជលក្ស្មី ដែលជាព្រះញាតិវង្ស ស្តេចស្រេស្ថវរ្ម័ន ខាងចេនឡា (ហៅថា **សូរ្យវង្ស វង្សព្រះអាទិត្យ)** ។ តាមសិលាចារឹកបក្សីចាំក្រុងក៏បាននិយាយដែរថា កូនចៅតសីកម្ពុជបានភ្ជាប់ញាតិវង្ស ខាងសូរ្យវង្ស (ខាងចេនឡា) ទៅនឹងសោមវង្ស (ខាងអាណាចក្រភ្នំ)

## គ.២-ការលេចឡើងនៃអាណាចក្រចេនឡា

អំពីចម្បាំងដែលកើតមានរវាងអាណាចក្រចេនឡា និងអាណាចក្រភ្នំបើតាមទស្សនៈរបស់អ្នកសិក្សាមួយចំនួនបានលើកឡើងថា ជាចម្បាំងដើម្បីបង្រួបបង្រួមអាណាចក្រទាំងពីរ ដើម្បីឲ្យក្លាយទៅជាអាណាចក្រតែមួយដែលឋិតនៅក្រោមការដឹកនាំគ្រប់គ្រងដោយអធិរាជមួយ ។ ក៏ប៉ុន្តែនៅមានទស្សន

ផ្សេងៗទៀត ដែលបានសន្និដ្ឋានទៅលើបុព្វហេតុនៃចម្បាំងរវាងអាណាចក្រចេនឡា និងអាណាចក្រភ្នំនេះ ដោយគេបានបញ្ចេញនូវសម្មតិកម្មខ្លះៗមួយចំនួនដូចខាងក្រោមៈ

អ្នកខ្លះបានយល់ថា **ព្រះបាទភវវរ្ម័ន** ដែលជាចៅរបស់ព្រះបាទរុទ្រវរ្ម័នបានលើកទ័ពមកវាយអាណាចក្រភ្នំនេះដើម្បីប្រឆាំងនឹងការប៉ុនប៉ងរបស់ក្រុមស្តេចគុណវរ្ម័ន ដែលត្រូវបានស្តេចរុទ្រវរ្ម័នធ្វើគត់ ដោយខ្លាចក្រែងបក្សពួកស្តេចគុណវរ្ម័នធ្វើការសងសឹកដណ្តើមរាជ្យបល្ល័ង្កទៅវិញ ។ បន្ថែមពីលើនេះទៅទៀតគេបានយល់ថា ប្រហែលជាមានទំនាស់ក្នុងរឿងសាសនាផងដែរ ព្រោះព្រះបាទរុទ្រវរ្ម័នជាកាន់សាសនាព្រះពុទ្ធសាសនា រីឯព្រះបាទភវវរ្ម័នជាអ្នកកាន់សាសនាឥស្សរ(ព្រហ្មញ្ញណ៍សាសនា)។

ដោយមានការនិយាយបែបនេះ ព្រោះគេសន្និដ្ឋានទៅលើពាក្យស្លោកនៅបូជនីយេសក៍ចិនឈ្មោះយីស៊ីងបានសរសេរនៅ**ចុងសតវត្សទី៧** ថា "ពីដើមនៅហ្វូណន ព្រះធម៌បានរីកចម្រើនលូតលាស់ ហើយមានការផ្សព្វផ្សាយទៅគ្រប់ទិសទី តែឥឡូវមានព្រះរាជាកំណាចមួយអង្គបានបំផ្លាញចោល" ព្រះរាជាអង្គនោះគឺសំដៅទៅលើព្រះបាទភវវរ្ម័ន ពីព្រោះចាប់ពីពេលនោះមក គេថាស្តេចនៅរដ្ឋចេនឡា សុទ្ធតែនិយមខាងសាសនាឥស្សរ។

ចំណែកលោក **Bernard Philippe Groslier** មានការយល់ផ្សេងពីនេះទៅវិញ ដោយលោកបានសរសេរនៅក្នុងសៀវភៅ Angkor Hommes Et Pireers លោកបាននិយាយថា មហន្តរាយដែលបណ្តាលមកពីទឹកជំនន់បានបំផ្លាញទីក្រុង និងប្រព័ន្ធបញ្ចេញបញ្ចូលទឹកក្នុងស្រែខូចអស់ផលដំណាំ ធ្វើឲ្យប្រជាជនភៀសខ្លួនទៅរស់នៅត្រង់ដីខ្ពស់នៅភាគខាងជើង ពេលនោះនៅភាគខាងត្បូង (តំបន់កូសាំងស៊ីន ក៏ក្លាយជាវាលល្បាប់មួយហើយមានសភាពស្ងាត់ជ្រងំ) ។ ប្រហែលជាឆ្លៀតឱកាសនាពេលនោះហើយ ដែលព្រះបាទភវវរ្ម័នបានវាយយកប្រទេសហ្វូណននៅ**ប្រមាណឆ្នាំ៥៥០** ដើម្បីបង្កើតទៅជាអាណាចក្រខ្មែរថ្មីមួយ គឺអាណាចក្រ ចេនឡាធំ។

## គ.៣-ចម្បាំងរវាងអាណាចក្រចេនឡា និងអាណាចក្រភ្នំ

**ព្រះបាទភវវរ្ម័ន**មានប្អូនមួយព្រះអង្គព្រះនាមថា **ចិត្រសេន (ឬចិត្រសេនា)** ដែលបានឡើងសោយរាជ្យក្រោយពីព្រះបាទភវវរ្ម័នសុគតទៅ ដោយមានព្រះនាមថា**ព្រះបាទមហេន្ទ្រវរ្ម័ន** (MANHENDRAVARMAN) ។

នៅពាក់កណ្ដាលទី២នៃ**សតវត្សរ៍ទី៦** ព្រះបាទភវវរ្ម័ននិងប្អូនរបស់ព្រះអង្គ ចិត្រសេន បានផ្ដើមធ្វើសង្គ្រាមវាយលុកទៅលើអាណាចក្រភ្នំ។ តាមសិលាចារឹករបស់**ព្រះបាទភវវរ្ម័ន និងចិត្រសេន** បានឲ្យដឹងថា ទ័ពរបស់ចេនឡាបានវាយសំរុកយ៉ាងខ្លាំងទៅលើពួកហ្វូណន ដោយចាប់ផ្ដើមពីភាគខាងជើងទៅត្បូងចុះទៅដល់ក្រចេះ ច្រាំងខាងកើតនៃទន្លេមេគង្គ និងទៅដល់បូរីរម្យនៅចន្លោះទន្លេមូន និងជួរភ្នំដងរែក និងទៅដល់មង្គលបូរីខាងលិចបឹងទន្លេសាប។នៅចំពោះមុខសភាពបែបនេះ ទ័ពខាងអាណាចក្រភ្នំទំនងជាចាញ់ដៃពួកអាណាចក្រចេនឡា ហើយត្រូវដកថយព្រមទាំងបានផ្លាស់រាជធានីពី **វ្យាធបុរៈ ពីតំបន់បាភ្នំ** ទៅតាំងនៅទិសខាងត្បូង គឺនៅណាហ្វូណា ដែលហៅថា **ក្រុងនរវរនគរ** (NARAVARNAGARA) នៅតំបន់អង្គរបូរី ខេត្តតាកែវ ។

## ២.រាជវង្សខ្មែរនៃអាណាចក្រចេនឡា

### ក.នយោបាយដឹកនាំគ្រប់គ្រងរបស់ព្រះបាទភវវរ្ម័នទី១

ក្រោយពីបានទទួលជោគជ័យ ក្នុងការវាយដណ្ដើមយកបានទឹកដីមកគ្រប់គ្រងហើយនោះ ទើបព្រះបាទភវវរ្ម័នទី១ឡើងសោយរាជ្យ ចាប់ពី**ឆ្នាំ៥៩៨ ដល់ឆ្នាំ៦០០** ។ គេបានឃើញសំណង់បាក់បែកជាច្រើន បានកើតមាននៅក្នុងសម័យចេនឡា ដែលគេសន្មតថាជាសំណង់នេះ ច្រើនកើតមានក្នុងរជ្ជកាល **ព្រះបាទភវវរ្ម័នទី១** ។ សំណង់ទាំងនោះត្រូវបានគេឃើញ មានដូចជានៅតាមដងទន្លេនមេគង្គ គឺក្រុមប្រាសាទនៅវត្តភូ ។

**ប្រាសាទនៅវត្តភូ**គឺជាសំណង់ប្រាសាទមួយ ដែលការកសាងឡើងសម្រាប់ឧទ្ទិសថ្វាយចំពោះព្រះសិរៈរបស់ព្រះបាទភវវរ្ម័នទី១។ ប្រាសាទបារាណ (PRASAT BARAN) ដែលស្ថិតនៅចន្លោះពីស្ទឹងត្រែង និងមាត់ទន្លេសេកុង និងអាស្រមមហាឫស្សី នៅជើងភ្នំហាន់ជ័យ ខេត្តកំពង់ចាម ជាសំណង់ដែលកើតមាននៅចន្លោះ រវាងសម័យហ្វូណន និងចេនឡា និងអាស្រម មហាឫស្សី

ស្ថិតនៅជើងភ្នំដា ស្រុកអង្គរបូរី ខេត្តតាកែវ ។

**ក្រុងបាសាទ នៅហាន់ជ័យ**នៅភាគខាងលិចអាងទន្លេមេគង្គ នៅខេត្តកំពង់ចាមសុទ្ធតែត្រូវបានគេសន្មតថាជាសំណង់កើតមាននៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ ។ គេបានរកឃើញសិលាចារឹកជាច្រើនដែលនិយាយអំពីការកសាងសមិទ្ធផលនានា ដូចជាប្រាសាទនិងសិលាចារឹករបស់ព្រះបាទភវវរ្ម័នទី១ នៅក្នុងសម័យចេនឡា ដូចជាសិលាចារឹកភ្នំបន្ទាយនាង នៅក្នុងខេត្តបាត់ដំបង នៅស៊ីថេប ក្នុងប្រទេសថៃ នឹងនៅកន្លែងផ្សេងៗទៀត ។ តាមរយៈសិលាចារឹកទាំងនោះ មានសិលាចារឹកខ្លះបាននិយាយផងដែរថា ព្រះបាទភវវរ្ម័នទី១ បានកសាងក្រុងមួយហៅថា **ក្រុងភវបុរៈ** (PHAVAPURA) ។

ទីតាំងនៅតំបន់ជុំវិញ**វត្តភ្នូបាសាក់ក្បែរមាត់ទន្លេមូន(ចំប៉ាសាក់)** ប្រទេសឡាវសព្វថ្ងៃ គឺជាទីតាំងមួយដែលត្រូវបានគេទទួលស្គាល់ថាមានកិត្តិនាមដ៏សំខាន់នៃការចាប់កំណើតរបស់រដ្ឋចេនឡា កម្ពុជទេស (ឈ្មោះប្រទេសកម្ពុជា[1]ក្រោយមក) ។ នៅតំបន់នេះជាតំបន់សម្បូរទៅដោយកូនភ្នំ ដែលនៅតំបន់ជុំវិញជើងភ្នំ ជាតំបន់នៃទីតាំងក្រុងចាស់ៗដែលមានដូចជា ក្រុងស្រេស្ថបុរៈ (SREHTHAPURA) របស់ព្រះបាទស្រេស្ថវរ្ម័ន និងក្រុងភវបុរៈ(BHAVAPURA)របស់ព្រះបាទភវវរ្ម័នទី១ ។

**ខ.វិសាលភាពនៃអាណាចក្រចេនឡា របស់ព្រះបាទភវវរ្ម័នទី១**

យើងបានដឹងរួចមកហើយថា **ចេនឡា** ដំបូងជាផ្នែកមួយនៃរដ្ឋនគរភ្នំដែលទឹកដីទាំងអស់នៃប្រទេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់នគរភ្នំ ។ នៅមានរដ្ឋតូចៗខ្លះទៀតដែលស្ថិតនៅឧបទ្វិបម៉ាឡេ និងនៅកន្លែងផ្សេងៗទៀត នៅតែមានការស្មោះត្រង់ជាងមួយនឹនគរភ្នំនៅឡើយ ទោះបីជាក្រោយពីអំណាចនៃរដ្ឋនគរភ្នំត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃនៃការគ្រប់គ្រងរបស់ចេនឡាក៏ដោយ ។ ហេតុដូចនេះហើយបានជាចាប់ពីរជ្ជកាលនៃព្រះបាទភវវរ្ម័នទី១និងបន្តមកដល់រាជ្យស្តេចក្រោយៗទៀត នៅតែបន្តការធ្វើសង្គ្រាមពង្រីកទឹកដីទៅគ្រប់ទិសឥតឈប់ឈរ ។ ចំពោះវិសាលភាពនៃអាណាចក្រចេនឡារបស់

**ព្រះបាទភវវរ្ម័នទី១** ត្រូវបានបង្ហាញដោយសិលាចារឹកជាច្រើន ដែលមាននៅក្នុងទឹកដីនៃប្រទេសកម្ពុជា ក៏ដូចជាកន្លែងដទៃៗទៀតក្រៅប្រទេសកម្ពុជាបច្ចុប្បន្ន ។

តាមរយៈសិលាចារឹកទាំងនោះ មានដូចជាសិលាចារឹកប្រាសាទវត្តភូ សិលាចារឹកនៅហាន់ជ័យ សិលាចារឹកថ្មក្រែ វត្តជ្រោយអំពិល វាលកន្ទេល ប្រាសាទព្រះធាតុ អាស្រម មហាឫស្សី **ប្រាសាទបារាណ** ។ នៅមានសិលាចារឹកនៅកន្លែងផ្សេងទៀត ដូចជានៅភ្នំបន្ទាយនាងភាគខាងជើងបាត់បង ភាគខាងលិចបឹងទន្លេសាបនិងនៅតំបន់ប្រសាទអកយំ ជាទីតាំងក្រុងអមរិន្ទ្របុរៈ នៅខាងលិចអង្គធំ ដែលតំបន់ទាំងនេះហើយបញ្ជាក់ពីវិសាលភាពនៃទីតាំងរបស់អាណាចក្រចេនឡា ក្រោមការគ្រប់គ្រងរបស់ព្រះបាទភវវរ្ម័នទី១ (PHAVAVARMAN I) ។

**គ.ព្រះបាទមហិន្ទ្រវរ្ម័ន (ចិត្រសេន)**

**តាមសិលាចារឹកនៅបងរមាស (ក្រោលរមាស)** ក្បែរសម្បូរព្រៃគុក ខេត្តកំពង់ធំ ចុះកាលកំណត់**ឆ្នាំ៥៩៨** ជាឆ្នាំនៃការសោយរាជ្យរបស់ព្រះបាទភវវរ្ម័នទី១ ។ នៅរជ្ជកាលនោះ ក្រៅពីក្រុងភវបុរៈ នៅមានការកសាងក្រុងផ្សេងទៀត ដូចជាក្រុងឥន្ទ្របុរៈ នៅភាគខាងត្បូងប្រាសាទសម្បូរព្រៃគុក ។ ព្រះបាទមហិន្ទ្រវរ្ម័ន (MEHENDRAVAMAN) ដែលត្រូវជាបងប្អូននឹង**ព្រះបាទភវវរ្ម័នទី១** បានសោយរាជ្យបន្តពី**ព្រះបាទភវវរ្ម័នទី១ ចាប់ពីឆ្នាំ៦០០ ដល់៦១៦** ។ តាំងពីនៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ ព្រះបាទមហិន្ទ្រវរ្ម័នបានរួមកសាងសិលាចារឹកជាភាសាសំស្ក្រឹត និងនិយាយអំពីការកសាងលិង្គ (សិវៈ) មាននៅតាមបណ្តោយទន្លេមេគង្គនៅតំបន់ក្រចេះ ស្ទឹងត្រែង និងនៅខាងលិចបូរីរម្យប្រទេសថៃសព្វថ្ងៃ។

**ព្រះបាទមហិន្ទ្រវរ្ម័ន** បានបន្តការគ្រប់គ្រងទឹកដីនៃអាណាចក្រចេនឡាពីព្រះបាទភវវរ្ម័នទី១ ដែលបានបង្កើតរាជវង្សថ្មីមួយហៅថាមហាឥន្ទ្រឬឥន្ទ្របុរៈ។ ព្រះបាទមហិន្ទ្រវរ្ម័ន បានចូលរួមជាមួយនឹង**ព្រះបាទភវវរ្ម័នទី១** ក្នុងការវាយរំដោះអាណាចក្រចេនឡាចេញពីការត្រួតត្រាដោយអាណាចក្រភ្នំ ។ នៅ

ក្នុងរជ្ជកាលរបស់ព្រះអង្គ មានការកសាងសិលាចារឹកផ្សេងៗទៀត ដូចជានៅត្រង់ពាមទន្លេមូន និងនៅសុរិន្ទ ។

**ដូចគ្នានឹងព្រះបាទភវវរ្ម័នទី១**ដែរ ព្រះបាទមហិន្ទ្រវរ្ម័នបានបន្តការពង្រីកទឹកដីទៅទិសលិច និងខាងត្បូងដោយមានសិលាចារឹកនៅតាមសសរថ្មធំៗនៅឯភូល្ហោន នៅភាគខាងឆ្វេងនៃទន្លេមេគង្គ នៅភាគខាងលើមាត់ទន្លេមូននៅប្រទេសឡាវ ដែលបានបញ្ជាក់ពីការកសាងលិង្គគិរិសរបស់ព្រះបាទមហិន្ទ្រវរ្ម័ន ក្នុងឱកាសដែលក្រោយពីព្រះអង្គបានធ្វើសង្គ្រាមទទួលបានជោគជ័យនៅតំបន់នេះ និងការគ្រប់គ្រងទឹកដីភាគខាងក្រោមនៃដងទន្លេមូន។

## ៣.វិវត្តន៍នយោបាយ សង្គមនៅសម័យចេនឡា

### ក-ព្រះបាទឦសានវរ្ម័នទី១

### ក.១ ការបញ្ចប់សង្គ្រាមរវាងអាណាចក្រភ្នំ និងចេនឡា

**ព្រះបាទឦសានវរ្ម័នទី១** ជាបុត្ររបស់ព្រះបាទមហិន្ទ្រវរ្ម័ន ដែលបានបន្តរាជ្យសម្បត្តិចាប់ពីឆ្នាំ៦១៦ ដល់ឆ្នាំ៦៣៥ ។ ដែលនៅសេសសល់ពីមុននៃអាណាចក្រភ្នំ ។ មានសិលាចារឹកជាច្រើនដែលបាននិយាយអំពីសកម្មភាពរបស់ព្រះបាទឦសានវរ្ម័នទី១ ដូចជាសិលាចារឹកនៅប្រាសាទភ្នំយ៉ង់ ដែលមានចុះកាលកំណត់**ឆ្នាំ៦២៤** នៅសម្បូណ៌ព្រៃគុកហ៍មានចុះកាលកំណត់**ឆ្នាំ៦២៧-៦២៨** នៅក្តីអង្គជំនីកមានចុះកាលកំណត**ឆ្នាំ៦២៨-៦២៩** ។

**នៅឆ្នាំ៦២៧ ព្រះបាទឦសានវរ្ម័នទី១** ទ្រង់បានបង្កើតទំនាក់ទំនងជាមួយនឹងប្រទេសចិនជាថ្មីទៀត ដោយព្រះចានចាត់តាំងរាជទូតខ្មែរ ឲ្យនាំព្រះរាជសារ និងព្រះរាជ បណ្ណាការផ្សេងៗ ទៅសុំចងសម្ព័ន្ធមិត្តនឹងព្រះចៅប្រទេសចិន ហើយព្រះចៅប្រទេសចិនក៏បានតបព្រះរាជសារមកវិញដែរ ។ នេះជាការបង្កើតទំនាក់ទំនងការទូតជាផ្លូវការរវាងប្រទេសខ្មែរ និងប្រទេសចិនលើកទី៥ ។

តាមប្រវត្តិសាស្ត្រ ឬរាជពង្សាវតារនៃរាជវង្សថាងរបស់ប្រទេសចិន បាននិយាយថា ព្រះបាទឦសានវរ្ម័នទី១ បានបញ្ចប់សង្គ្រាមជាមួយអាណាចក្រភ្នំនៅពេលដែលព្រះអង្គវាយដណ្តើមយកបានរាជធានីនៅភាគខាងត្បូង ដែល

ចិនហៅថារាជធានី ណាហ្វណា (NAFUNA) ជាក្រុង នរវរនគរ នៅអង្គរបូរី ខេត្តតាកែវ។

### ក.២ ការផ្លាស់ប្តូរទីតាំងរាជធានី

ចំពោះទីតាំងរាជធានីដំបូងរបស់ចេនឡា គឺនៅឯវត្តភូ ចំប៉ាសាក់ ឬនៅតំបន់ស្ទឹងត្រែង ។ ក្រោយពីបានធ្វើសង្គ្រាមពង្រីទឹកដី ក៏ដូចជាពង្រីកទីតាំងអាណាចក្រចេនឡា ព្រះបាទឦសានវរ្ម័នទី១ បានផ្លាស់រាជធានីពីភាគខាងជើង មកតាំងនៅតំបន់មួយដែលស្ថិតនៅខាងជើងកំពង់ធំ គឺនៅឦសានបុរៈ ដែលត្រូវនឹងរមណីយដ្ឋានសម្បូណ៌ព្រៃគុកហ៍ ដែលនៅទីនោះមានសល់សំណង់បែកបាក់ជាច្រើន បានបន្សល់ទុកដូចជានៅតំបន់អង្គរបូរីដែរ ។ តាមពិតនៅតំបន់សម្បូណ៌ព្រៃគុកហ៍ជាទីតាំងក្រុងចាស់មួយដែរ ដែលមានឈ្មោះថា អនិន្ទិតបុរៈ នៃក្សត្រពាលាទិត្យា។

តាមសិលាចារឹកបាននិយាយថាក្សត្រពាលាទិត្យា ជាក្សត្រក្នុងរាជវង្សកៅណ្ឌិន្យនិងសោមា ទំនងក្សត្រពាលាទិត្យាបានគ្រប់គ្រងទឹកដីនៃអាណាចក្រនៅតំបន់នេះ ដែលក្រោយមកត្រូវបានវាយដណ្តើមយកដោយស្តេចភវវរ្ម័នទី១ និងមហិន្ទ្រវរ្ម័ន ហើយបានបន្តការគ្រប់គ្រងទឹកដីនេះរហូតមកដល់ព្រះឦសានវរ្ម័នទី១ទៀត ដោយព្រះបាទឦសានវរ្ម័នទី១ ទ្រង់បានហៅក្រុងថ្មីនេះថាក្រុងឦសានបុរៈ។

### ក.៣ ការវាយដណ្តើមកាន់កាប់ទឹកដីរបស់ព្រះបាទឦសានវរ្ម័នទី១

តាមសិលាចារឹកនានាបាននិយាយថា នៅក្នុងរជ្ជកាលនៃព្រះបាទឦសានវរ្ម័នទី១ មានទីតាំងក្រុងផ្សេងៗមួយចំនួនទៀតក្រៅពីទីតាំងក្រុងអនិន្ទិតបុរៈ(CAKRANKARPURA) ដែលនៅតំបន់ខាងលិចដីក្រែង ខាងជើងបឹងទន្លេសាប មានក្រុងអាមូគ្គបុរៈ (AMOGHOPURA) ដែលស្ថិតនៅបាត់ដំបង និងមានក្រុងភីមៈបុរៈ (BHIMAPURA)ជាទីតាំងមួយនៅឯភិម៉ៃ ប្រទេសថៃសព្វថ្ងៃព្រមទាំងអមរិន្ទ្របុរៈ ដែលនៅខាងលិចបារាយណ៍ទឹកថ្លា ឬ បារាយណ៍ខាងលិច ដែលក្រោយមកជាទីតាំងនៃរាជធានីបណ្តោះអាសន្នមួយរបស់ព្រះបាទជ័យវរ្ម័នទី២

ក្រៅពីតំបន់ទាំងនេះនៅភាគខាងលិចប្រទេស គឺតំបន់វាលទំនាបនៃទន្លេមេណាម ប្រទេសថៃសព្វថ្ងៃ ដែលមានសិលាចារឹកនៅច័ន្ទប៊ុន ក៏បាននិយាយពីការគ្រប់គ្រងទឹកដីដោយព្រះបាទឦសានវរ្ម័នទី១ នៅទីនោះដែរ។ នៅមានសិលាចារឹកពីផ្សេងទៀតនៅខេត្តក្រាប៊ីន (KRABIN) នៅក្បែរព្រំប្រទល់ខ្មែរ-ថៃ នៅខាវណយ (Khao Noi) ឆ្នាំ៦៣៧ និងខាវរ៉ាង (Khao Rang)ដែលមានចុះកាលកំណត់ ឆ្នាំ៦៣៩ ។ ព្រះបាទឦសានវរ្ម័នទី១ បានធ្វើការវាយដណ្តើមកាន់កាប់ទឹកដីនៅភាគខាងលិច ហើយបានឡើងទៅដល់អាណាចក្រមននៅត្រង់ទ្វារវតី (Dvaravati) ដែលមានទីតាំងនៅតាមបណ្តោយដងទន្លេមេណាមនិងភាគខាងលើដងទន្លេមូន ។

**នៅក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១** ការគ្រប់គ្រងទឹកដីមានភាពធំទូលាយ ព្រោះនៅពេលនោះអាណាចក្រតូចៗដែលនៅសេសសល់ពីនគរភ្នំទាំងប៉ុន្មាន ត្រូវបានប្រមូលយកមកគ្រប់គ្រងនៅក្នុងអាណាចក្រចេនឡាតែមួយ។ ក៏ប៉ុន្តែការគ្រប់គ្រងទឹកដីដ៏ធំទូលាយនេះ បើសិនជាអំណាចគ្រប់គ្រងកណ្តាលពុំមានភាពរឹងមាំទេ នោះនឹងធ្វើឲ្យមានការប្រេះឆាគ្នា ហើយឈានទៅរកការគ្រប់គ្រងជារដ្ឋដោយឡែកៗពីគ្នាទៅវិញ។

**ខ.ព្រះបាទភវវរ្ម័នទី២** (គ.ស៦៣៩...)

**ព្រះបាទភវវរ្ម័នទី២** ពុំមែនជាបុត្ររបស់ព្រះបាទឦសានវរ្ម័នទី១ទេ ហើយក៏ពុំដឹងថាមានជាប់នឹងញាតិវង្សត្រកូលខាងណាដែរ ។ ព្រះបាទឦសានវរ្ម័នទី១ ទំនងជាពុំមានបុត្រស្នងរាជ្យបន្ត ហេតុនេះហើយក្រោយពីរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ស្តេចដែលសោយរាជ្យបន្តគឺមានព្រះនាមថាព្រះបាទភវវរ្ម័នទី២ ។ **ព្រះបាទភវវរ្ម័នទី២** បានឡើងសោយរាជ្យនៅ**ឆ្នាំ៦៣៩ ដល់ឆ្នាំ៦៥៧** ទ្រង់បានបន្សល់ទុកនូវសិលាចារឹកជាច្រើន ក្នុងនោះមានសិលាចារឹកមួយដែលគេបានរកឃើញនៅតំបន់តាកែវ មានចុះកាលកំណត់ឆ្នាំ៦៣៩ ជាសិលាចារឹករបស់ព្រះអង្គ ។ ក្រៅពីនោះនៅមានសិលាចារឹកផ្សេងទៀតដូចជានៅ ភ្នំព្រះវិហារកំពង់ឆ្នាំង ត្រពាំងមាស និងនៅភ្នំបាយ៉ង់ ។ ប្រាសាទភ្នំបាយ៉ង់មានសិលាចារឹកដែលបាននិយាយអំពីព្រឹត្តិការណ៍នានារបស់ព្រះបាទភវ

វរ្ម័នទី២ ថែមទាំងបញ្ជាក់ទៀតថា រាជធានីរបស់ព្រះបាទភវវរ្ម័នទី២ពេលនោះ ទំនងជានៅអង្គបូរី ខេត្តតាកែវ ។

**គ.ព្រះបាទជ័យវរ្ម័នទី១** (គ.ស ៦៥៧-៦៨១)

**ព្រះបាទជ័យវរ្ម័នទី១** ជាបុត្ររបស់ព្រះបាទភវវរ្ម័នទី២ ហើយបានឡើងសោយរាជ្យបន្តពីព្រះអង្គ នៅរវាង **គ.ស៦៥៧** ។ ចាប់តាំងពីដើមរជ្ជកាល **គ.ស៦៥៧** រហូតដល់ចុងរជ្ជកាលរបស់ព្រះអង្គគ.ស៦៨១ មានសិលាចារឹកជាច្រើនដែលបាននិយាយអំពីការកសាងសមិទ្ធផលនានារបស់ ព្រះបាទជ័យវរ្ម័នទី១ មានដូចជាប្រាសាទនៅតំបន់វ្យាធបុរៈ និងនៅវត្តភូ។

**ព្រះបាទជ័យវរ្ម័នទី១** នៅតែបន្តនយោបាយគ្រប់គ្រងទឹកដីទៅទិសខាងត្បូង និងភាគខាងលិច គឺតំបន់អាងទន្លេមេណាមភាគខាងកើតព្រមទាំងតំបន់ខាងលើនិងភាគកណ្តាលប្រទេសឡាវ ។ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ ការគ្រប់គ្រងអាណាចក្រត្រូវបានបែងចែកជាផ្នែកផ្សេងៗ និងមានអាណាចក្រតូចៗ ដែលឋិតនៅក្រោមការគ្រប់គ្រងដោយព្រះអង្គដែលផ្នែកទាំងនោះមានដូចជា តំបន់វត្តភូរហូតដល់ដីសណ្តរ គឺភាគខាងកើតអាងទន្លេមេគង្គ មកដល់ស្ទឹងត្រែង ក្រចេះ រវាងបាភ្នំ និងបន្ទាយព្រៃនគរ (ខេត្តកំពង់ចាម) មានទីក្រុងសំខាន់គឺសម្ភុបុរៈនៅសម្បូរណ៍។ នៅផ្នែកខាងលិចអាងទន្លេមេគង្គ ទៅដល់អង្គរបុរី និងមួយផ្នែកទៀតទៅបាត់ដំបងនិងភាគខាងជើងបឹងទន្លេសាប។

**៤.ការធ្លាក់ចុះឪនថយនៃអាណាចក្រចេនឡា**

**ក.ព្រឹត្តិការណ៍ក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី១**

ទីតាំងរបស់ព្រះបាទជ័យវរ្ម័នទី១ទំនងជានៅតំបន់បន្ទាយព្រៃនគរនិងបាភ្នំ វ្យាធបុរៈ ។ ចាប់ពីក្រោយ**ឆ្នាំ៦៨១** គេពុំបានឃើញសិលាចារឹកឬឯកសារផ្សេងៗ ដែលនិយាយអំពីសកម្មភាពនានារបស់**ព្រះបាទជ័យវរ្ម័នទី១**ឱ្យបានច្បាស់លាស់ទេ ។ តាមការសន្និដ្ឋានថា ក្រោយពីព្រះបាទជ័យវរ្ម័នទី១ ចូលទីវង្គតនៅ**ឆ្នាំ៦៨១** ទំនងជាពុំមានបុត្រស្នងរាជ្យបន្តពីព្រះអង្គទេ ហេតុនេះហើយទើបមានព្រះនាមជាក្សត្រីជ័យទេវី ដែលការសន្និដ្ឋានត្រូវពន្យល់ដោយសិលាចារឹកមួយនៅបារាយណ៍ខាងលិច ឬបារាយណ៍ទឹកថ្លា ។

ក្រោយមកគេបានឃើញសិលាចារឹកនៅតំបន់បារាយណ៍ខាងលិច ឬបារាយណ៍ទឹកថ្លា នៅខាងលិចអង្គធំត្រូវបានបកស្រាយពន្យល់ដោយលោក ហ្សឺក សឺដែល ដែលនិយាយពីការគ្រប់គ្រងអាណាចក្រចេនឡាដោយក្សត្រី ជ័យទេវី (តាមសៀវភៅ TRANSACTIONS AMERICAN PHILOSOPHICAL SOCIETY THE "ANCIENT KHMER EMPIRE" និយាយថា ជាមហេសីរបស់ព្រះបាទជ័យវរ្ម័នទី១ ) តែតាមសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់**លោក ត្រឹង ងា ឆ្នាំ១៩៧៣** ថាជារាជបុត្រី។ ដោយតាមរយៈសិលាចារឹកនេះ បាននិយាយពីការត្អូញត្អែររបស់ព្រះនាងជ័យទេវី (JAYADAVI) អំពីភាពច្របូកច្របល់ក្នុងចិត្ត និងទុក្ខវេទនា ក្នុងការគ្រប់គ្រងនគរមានកើតកលិយុគ ។ តាមការពន្យល់នេះប្រហែលជានៅពេលនោះ នគរមានចម្បាំងនឹងគ្នារវាងក្សត្របូរីផ្សេងៗនៅក្នុងអាណាចក្រចេនឡាដែលនាំឱ្យឈានទៅដល់ការបែកបាក់គ្នា បណ្តាលឱ្យមានការបែងចែកប្រទេសចេនឡាធំជាពីរក្នុងអំឡុងដើម**សតវត្សរ៍ទី៨(៧០៦)**។

**ខ.ការបែកបាក់ និងការបែងចែកអាណាចក្រចេនឡា**

ក្រោយពីមានការបែកខ្ញែកគ្នា ប្រទេសចេនឡាត្រូវបានបែងចែកជាពីរផ្នែក គឺផ្នែកខាងជើង និងផ្នែកខាងត្បូង ដែលផ្នែកខាងជើងជាតំបន់ដែលសម្បូរទៅដោយភ្នំ កូនភ្នំ ជ្រលងភ្នំ និងខ្ពង់រាប ត្រូវបានហៅថា ចេនឡាដីគោក។ ចេនឡាដីគោកមានវិសាលភាពលាតសន្ធឹងទៅលើប្រទេសឡាវ ភាគកណ្តាលនិងភាគខាងត្បូងសព្វថ្ងៃមានព្រំប្រទល់ចាប់ពីជួរភ្នំដងរែក និងល្បាក់ខោននៃប្រទេសឡាវ ទៅភាគខាងជើងទល់នឹងរដ្ឋណានឆាវរបស់ថៃ នៅតំបន់យុនណាន់ ជាខេត្តរបស់ចិនភាគខាងត្បូង ។ ផ្នែកខាងត្បូង ជាតំបន់ដែលសម្បូរទៅដោយវាលទំនាប ទន្លេ ស្ទឹង បឹងបួរ និងមានសមុទ្រព័ទ្ធជុំវិញ ដែលត្រូវបានហៅថាចេនឡាទឹកលិច ។ ផ្នែកនេះត្រូវគ្របដណ្តប់ទៅដោយអាងទន្លេមេគង្គ ចាប់ពីល្បាក់ខោនប្រទេសឡាវ ចុះមកភាគខាងត្បូងទល់នឹងសមុទ្រ។

ចំពោះទីតាំងនៃរាជធានីរបស់អាណាចក្រទាំងពីរ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយមានការលំបាកក្នុង

ការសន្និដ្ឋានឱ្យបានច្បាស់លាស់ណាស់ ដោយអ្នកខ្លះសន្មតថានៅត្រង់នេះ អ្នកខ្លះទៀតថា នៅត្រង់នោះ មិនប្រាកដច្បាស់លាស់ឡើយ។

**នៅឆ្នាំ១៩០៤ លោក ហ្ស៊ែក ម៉ាស្ពេរ៉ូ** បានធ្វើការសិក្សាទៅលើអត្ថបទសិលាចារឹករបស់ព្រះបាទយសោវរ្ម័នទី១ ដែលនិយាយពីការគ្រប់គ្រងអាណាចក្រទាំងពីរនៅសម័យនោះ ប្រហែលជាមុនពីរសតវត្សរ៍ ទីតាំងមួយគឺការគ្រប់គ្រងមាននៅឯ វ្យាធបុរៈ ដែលក្រោយមកត្រូវសន្មតថា នៅឯអង្គបូរី ខេត្តតាកែវ ។ មួយផ្នែកទៀតការគ្រប់គ្រងមាននៅឯ សម្ភុបុរៈ (SAMBHUPURA) ដែលបច្ចុប្បន្នត្រូវនឹង ស្រុកសម្បូរ ខេត្តក្រចេះ ។ ជាមួយនោះដែល**លោក ប៉ូល ពេលីយ៉ូត** ក៏បានយល់ស្របទៅនឹងទស្សនៈរបស់**លោក អ.អែម៉ូញេ** ដែលបានិយាយថាទីតាំងរាជធានីរបស់អាណាចក្រចេនឡាទឹកលិចនៅឯ **វ្យាធបុរៈ** ហើយបានបញ្ជាក់ថាសម្បូរទំនងជាទីតាំងនៃចេនឡាដីគោកដោយហេតុថា **សម្ភុបុរៈ** នៅឆ្ងាយពីទីតាំង**វ្យាធបុរៈ**។

ក្រោយមក**លោក ព្សែរ ឌុយប៉ុង** បានបង្ហាញភស្តុតាងនៃគំនិតរបស់លោកដែលបានបញ្ជាក់ថាចេនឡាដីគោកក្រោយពីឆ្នាំ៧០៧ មានទីតាំងនៅឯដើមកំណើតចេនឡាពីមុន គឺក្នុងរជ្ជកាល**ព្រះបាទភវវរ្ម័នទី១** ដែលមានឈ្មោះថា **ភវបុរៈ** នៅតំបន់បាសាក់ ឬប៉ាកសេ និងផ្នែកខាងក្រោមទន្លេមូន ។ គេក៏បាននិយាយផងដែរថា កាលនៅក្រោមការគ្រប់គ្រងដោយ**ព្រះបាទភវវរ្ម័នទី១** និងរជ្ជកាលក្រោយៗមកទៀត មានការវាយដណ្ដើមកាន់កាប់នៅភាគខាងត្បូង ហើយតំបន់**ភវបុរៈ**ត្រូវពង្រីកកាន់តែធំនៅលើទីតាំងអតីត**ក្រុងស្រេស្ឋបុរៈ**។ ក្រោយការវាយដណ្ដើមកាន់កាប់ទឹកដី មានដូចជានៅតំបន់**សម្ភុបុរៈ វ្យាធបុរៈ ពាលាទិត្យបុរៈ** (BALADITYAPURA) ត្រូវបានបង្រួបបង្រួមជាតំបន់ចេនឡាទឹកលិច ។ តាមការសន្និដ្ឋានខាងលើនេះ **លោក ហ្ស៊ែក សឺដែស** ក៏បានយល់ស្របដែរថាទីតាំងរាជធានីនៃអាណាចក្រ ចេនឡាដីគោក គឺនៅឯ**ភវបុរៈ** (BHAVAPURA) ។

**ខ.១ ចេនឡាដីគោក**

អំពីប្រវត្តិចេនឡាដីគោកនៅអំឡុងសតវត្សរ៍ទី៨ ពុំសូវមានព័ត៌មាន

ច្រើនដូចជាចេនឡាទឹកលិចទេតែគេបានដឹងតាមរយៈប្រវត្តិសាស្រ្តចិន និយាយថានៅ**គ.ស៧១៧** ចេនឡាដីគោកមានការបញ្ជូនទូតទៅកាន់ប្រទេសចិនជាច្រើនលើក ។ ចេនឡាដីគោកនេះត្រូវបានចិនហៅថាវិនតាន (Wen Tan) ។ នៅ**គ.ស៦២១** ចិន បានលើកទ័ពមកវាយយកតំបន់មួយហៅថាអាណ្ណាម (តាមពិតតំបន់តុងកឹង ពីមុនឈ្មោះស្រុកយួន ហៅថាយ៉ាវចូវ)ដែលជាទីតាំងរស់នៅរបស់ពួកយួន។ ក្រោយពីព្រឹត្តិការណ៍នេះ ពួកយួនបានចងសម្ព័ន្ធភាពជាមួយ ចេនឡានិងចម្ប៉ា ហើយនៅ**គ.ស៧២២** រដ្ឋចេនឡាដីគោក (វិនតាន) បានចូលរួមចម្បាំងជាមួយពួកយួនដោយពួកយួនបានបះបោរធ្វើសង្រ្គាមប្រឆាំងនឹងការគ្រប់គ្រងរបស់ចិន ក្នុងរាជ្យវង្សថា ។ **នៅគ.ស៧៥៣** ចេនឡាដីគោកមានការបញ្ជូនទូតទៅកាន់ប្រទេសចិន ក្រោមកិច្ចដឹកនាំ នៃរាជបុត្ររបស់ព្រះរាជានៃអាណាចក្រនេះពេលនោះចិនកំពុងមានសង្គ្រាមមួយនៅតំបន់ណាន ឆាវ ហើយចង់ឪ្យអាណាចក្រវិនតាន ជួយដល់ខ្លួនក្នុងការធ្វើសង្គ្រាមនេះ។ **នៅគ.ស៧៥៤** រាជបុត្រនៃអាណាចក្រចេនឡាដីគោកបានលើកទ័ពទៅជួយចិន ក្នុងការវាយលុកតំបន់ណានឆាវ។ **នៅគ.ស៧៩៩** អាណាចក្រចេនឡាដីគោកបានបញ្ជូនទូតទៅកាន់ប្រទេសចិនទៀត។ គេបានសន្មតថារាជធានីនៃអាណាចក្រចេនឡាដីគោក ស្ថិតនៅត្រង់មជ្ឈមណ្ឌលនៃអាណាចក្រដើមគឺ ភវបុរៈ ហើយព្រះរាជាដែលមានមហិទ្ធិរិទ្ធ និងគ្រប់គ្រងនៅអាណាចក្រនេះ ត្រូវបាន
គេសន្មតថាជា **ព្រះបាទជ័យសិង្ហវរ្ម័ន** ដោយគេបានរកឃើញសិលាចារឹកមួយផ្ទាំងដែលនិយាយអំពីក្សត្រអង្គនេះ នៅមុំនគររាជសីមាប្រទេសថៃសព្វថ្ងៃ។

**ខ.២ ចេនឡាទឹកលិច**

ក្រោយពីការបែងចែកអាណាចក្រចេនឡាធំជាពីរ (ជាចេនឡាដីគោក និងចេនឡាទឹកលិច) រដ្ឋចេនឡាទឹកលិចក៏មិនអាចរក្សាការឯកភាពគ្នាបានយូរអង្វែងទេ រដ្ឋចេនឡាទឹកលិចនេះត្រូវបានបែងចែកទៅជាក្សត្របូរីតូចៗតទៅទៀត ដែលយ៉ាងហោចនាស់ថាមានដល់ទៅ៥ក្សត្របុរី មានដូចជាក្សត្របូរី អនិន្ទិតបុរៈ សម្ភុបុរៈ និងក្សត្របូរីផ្សេងៗទៀត ដែលស្គាល់ទីតាំងពុំច្បាស់

លាស់។ ចំពោះទីតាំងនៃរាជធានីត្រូវបានគេសន្មតថានៅសម្ភុបុរៈ (ស្រុកសម្បូរណ៍ត្រើយខាងកើតទន្លេមេគង្គក្នុងខេត្តក្រចេះ) ។ សូមបញ្ជាក់ថានៅដើមសតវត្សរ៍ទី៨ ព្រះអង្គម្ចាស់បុស្ករក្ស ដែលមានដើមកំណើតនៅអនិន្ទិតបុរៈ បានយាងទៅសោយរាជ្យនៅសម្ភុបុរៈ ជាទីដែលព្រះអង្គបន្សល់ ទុកនូវសិលាចារឹក ចុះកាលកំណត់**គ.ស៧១៦** នៅត្រង់ប្រាសាទព្រះធាតុកូនពីរ ។ ព្រះអង្គម្ចាស់បុស្ករក្ស ជាប់ខ្សែស្រឡាយសាច់ញាតិទៅនឹងព្រះបាទ ពាលាទិត្យា ដែលបានសោយរាជ្យនៅអនិន្ទិតបុរៈ ហើយបានអះអាងថាជាកូនចៅរាជ្យវង្សរបស់ព្រះបាទកៅណ្ឌិន្យ និងនាគីសោមា និងក្រោយមកបានបន្តពូជពង្សសោយរាជ្យ និងក្រោយមកបានបន្តពូជពង្សសោយរាជ្យនៅអង្គរ។ ព្រះបាទពាលាទិត្យា បានកសាងក្រុងមួយហៅថា ពាលាទិត្យបុរៈ ដែលចិនបានចាត់ទុកថាជារាជធានីមួយរបស់ចេនឡា (ចិនហៅថា ក្រុងប៉ូឡូទីប៉ូ)។ មានសិលាចារឹកមួយពុំមានចុះកាលកំណត់ច្បាស់លាស់ សរសេរជាភាសាសំស្ក្រឹតដែលគេបានរកឃើញនៅវត្តស្រែបេង ក្នុងភូមិអូឡាម ខេត្តជូដុកនៅដីសណ្តូ ។ តាមរយៈសិលាចារឹកនេះមាននិយាយអំពីក្សត្រពាលាទិត្យា ។

**នៅពាក់កណ្តាលទី២ នៃសតវត្សរ៍ទី៨** ចេនឡាមានការកសាងសិលាចារឹកជាច្រើនជាពិសេស នៅតំបន់សម្ភុបុរៈ ដែលគេបានរកឃើញនៅប្រាសាទព្រះធាតុព្រះស្រីក្នុងស្រុកត្បូងឃ្មុំមានចុះកាលកំណត់ **គ.ស៧៧០** និងមួយទៀតនៅតំបន់ក្រចេះ មានចុះកាលកំណត់ **គ.ស៧៨១** ព្រមទាំងមាននៅប្រាសាទ **តាគាម** នៅខេត្តសៀមរាម ។

### គ.ចេនឡាទឹកលិចក្រោមអំណាចត្រួតត្រារបស់ជ្វា

នៅអំឡុងសតវត្សរ៍ទី៨ប្រទេសខ្មែរ(ចេនឡា) ហាក់ដូចជាគ្មានស្ថិរភាពខាងនិយាយបាយ ដោយសារតែមានសង្គ្រាមដណ្តើមកាន់កាប់ទឹកដីរវាងគ្នា និងគ្នាបញ្ហានេះធ្វើឪ្យតំបន់ឬរដ្ឋតូចៗមួយចំនួនមិនសប្បាយចិត្តបណ្តាលឪ្យមានការឈានទៅរកជម្លោះនិងបែកបាក់ផ្ទៃក្នុង ។ ការបែកបាក់គ្នានេះធ្វើឪ្យឫទ្ធានុភាព និងអំណាចដែលធ្លាប់មានពីមុននោះត្រូវចុះទន់ខ្សោយចំពោះមុខពួកបរទេសមើលងាយ និងហ៊ានចូលលុកលុយរាតត្បាតតាមអំពើចិត្តដែល

ក្នុងនោះមានដូចជាពួកជ្វា **ស្រីវិជ័យនៃរាជវង្ស សៃលេន្ទ្រ** (SAI-LENDRA) នៅកោះជ្វា ។ ជនជាតិជ្វាបានបង្កើតរាជវង្ស **សៃលេន្ទ្រ** ដែលជារាជវង្សថ្មីមួយមានអំណាចឫទ្ធានុភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានទីតាំងនៅកោះជ្វា ក្បែរតំបន់ មួយបច្ចុប្បន្នហៅថា **ប៉ាឡេមបាង** (PALEMBANG) ។

តាមរយៈសិលាចារឹកមួយមានចុះកាលកំណត់គ.ស៧៧៨ នៅក្បែរទីក្រុង **ហ្សកការតា** នៅកណ្តាលកោះជ្វាតាមរយៈសិលាចារឹកនោះបាននិយាយពីការកសាងពុទ្ធរូបតារា (TARA) ដោយស្តេច **ប៉ាណាមការាណា** (PANAMKARANA) ហៅថាមហារាជ្យ (MAHARAJA) ដែលក្រោយមកត្រូវបានបង្កើតជារាជវង្ស**សៃលេន្ទ្រ** នេះឡើងដែលសៃលេន្ទ្រនេះមានន័យដូចជាស្តេចក្រុងភ្នំដែរ។ រាជវង្ស សៃលេន្ទ្រ ដែលសោយរាជ្យនៅកោះជ្វា ក៏មានងារជារាជវង្សស្ថាបនិកដ៏ល្បីល្បាញផងដែរដូចជាការកសាង ប្រាសាទបូរ៉ូប៊ូដូរ(BORO BUDUR)ដែលជាប្រាសាទដ៏ល្បីល្បាញនៅប្រទេសឥណ្ឌូនេស៊ី ។ តាមរយៈឥទ្ធិពលនៃរាជវង្សសៃលេន្ទ្រនេះពួកចោរសមុទ្រជ្វា បានចូលមករាតត្បាតនៅតាមឆ្នេរនានានៅអាស៊ីអាគ្នេយ៍ និងធ្វើសកម្មភាពឆក់ប្លន់ទ្រព្យសម្បត្តិ ដុតបំផ្លាញទីក្រុងនានាតាមទំនើងចិត្ត ។ **នៅគ.ស៧៧៤** ពួកចោរសមុទ្រជ្វានេះបានលើកទ័ពចូលមកវាយលុកលុយទីតាំងកោះត្រឡាច ហើយបានតាំងមូលដ្ឋាននៅទីនោះ ។ **នៅឆ្នាំ៧៨៧** ពួកចោរសមុទ្រជ្វានេះក៏បានលើកទ័ពមករាតត្បាតនៅតាមឆ្នេរអាណ្ណាម និងចម្ប៉ា ។ តាមសិលាចារឹកចាមយ៉ាងទីគូហ (YANGTIKUH) សិរៈបាននិយាយថាមានប្រាសាទនិងបូជនីយដ្ឋាន នៅក្បែរក្រុងវីរបុរៈ (VARAPURA) ត្រូវរងទទួលនូវការដុតបំផ្លាញដោយពួកកងទ័ពជ្វា ។ បន្ទាប់ពីបានរាតត្បាត និងបំផ្លិចបំផ្លាញនៅតាមឆ្នេរនានា ហើយពួកចោរសមុទ្រជ្វាក៏បានបន្តដំណើរចូលមកដល់ពាម និងតាមទន្លេមេគង្គឡើង ទៅដល់ក្រុងសម្ភុបុរៈ ហើយបានធ្វើការឆក់ប្លន់ដុតបំផ្លាញទីក្រុង និងកាប់សម្លាប់ប្រជាជនតាមអំពើចិត្ត ។ ជាមួយនឹងនោះពួកជ្វាក៏ចាប់យកប្រជាជនខ្លះ និងបានកាត់ព្រះសិរព្រះរាជាខ្មែរ (ចេនឡា) រហូតដល់ពេលមានការរំដោះប្រទេសជាតិបានវិញឱ្យរួចផុតពីការត្រួតត្រារបស់ពួកនេះ ដោយព្រះរាជាខ្មែរ មួយអង្គគឺ **ព្រះបាទ**

**ជ័យ**

**វរ្ម័នទី២ នៅគ.ស៨០២។**

ចំពោះការឈ្លានពាន និងការចូលលុកលុយពីសំណាក់ពួកជ្វានៅពេលនោះមកលើអាណាចក្រចេនឡាដែលបានកាត់យកព្រះសិរព្រះរាជាខ្មែរ ទៅផងមានមតិខ្លះបានយល់ថាជាការទាមទារយកគេរមតិដូនតារបស់ពួកគេ គឺសៃលេន្ទ្រវរ្ម័ន (SAILENDRAVARAMAN) ដែលរាជវង្សសៃលេន្ទ្រ នេះបានប្រកាសខ្លួន ថាជាស្តេចភ្នំ និងមានឋានន្តរនាមដូចស្តេចអាណាចក្រភ្នំនៅប្រទេសខ្មែរដែរ។

**៥.បំរែបំរួលប្រជាករ និង ស្ថានភាពសង្គម**

ការលូតលាស់ពូជពង្សនៃជនជាតិខ្មែរសម័យនោះពុំទាន់ធាត់ធំទេ ជាកត្តាចំបងធ្វើឲ្យមានការបែកបាក់ផ្ទៃក្នុងប្រទេស។ ម្យ៉ាងទៀត លក្ខណៈពិសេសនៃសេដ្ឋកិច្ចរបស់ប្រទេស និងការវិវត្តខាងនយោបាយនៃប្រទេសពឹងផ្អែកទៅលើដីស្រែចំការ។ វាលទំនាបទន្លេមេគង្គ សំបូរថ្លុកត្រពាំង។ ដូចនេះនៅនគរភ្នំ ផ្ទៃដីសំរាប់ដាំស្រូវមានតូច តំរូវឲ្យមានការវាតដីជាបន្តបន្ទាប់ ដោយវិធីបង្ខិតបង្ខំកំលាំងទាសាទាសី ដែលជាកសិករ។ ដីស្រែចំការគឺជាកម្មសិទ្ធិរបស់រដ្ឋ ហើយសំណង់ទំនប់ទឹក និងប្រព័ន្ធបង្ហូរទឹក គឺកសាង និងដឹកនាំដោយរាជការ។

ចេនឡាមានការរីកចំរើនខ្លាំងខាងវិស័យសេដ្ឋកិច្ច។ រីឯអាណាចក្រភ្នំវិញរងគ្រោះធម្មជាតិបណ្តាលឲ្យសេដ្ឋកិច្ចធ្លាក់ចុះ។ នេះជាឱកាសល្អសំរាប់រាជវង្សខាងចេនឡាធ្វើសញ្ជ័យលើអាណាចក្រភ្នំ។ ព្រះរាជាចេនឡា ព្រះបាទភវវម្ម័ និងប្អូនចិត្រសេនា បានវាយលុកអាណាចក្រភ្នំប្រហែលរវាង **គ.ស៥៥០**។ អាណាចក្រភ្នំក៏ធ្លាក់ក្នុងកណ្តាប់ដៃរាជវង្សនៅចេនឡាគឺព្រះបាទភវវម្ម័ទី១ ហើយអាណាចក្រភ្នំក៏ប្រែឈ្មោះជា កម្ពុជា។**នៅសតវត្សទី៨ រវាងឆ្នាំ ៧០៦** កម្ពុជាត្រូវបានបែងចែកជាពីរគឺចេនឡាដីគោកដែលសំបូរភ្នំ និងជ្រលងភ្នំ និងចេនឡាទឹកលិច ដែលសំបូរទៅដោយបឹងនិងមានឆ្នេរសមុទ្រ។

ការបែកបាក់ផ្ទៃក្នុងរវាងចេនឡាទាំងពីរ ជាការបើកឱកាសឲ្យពួកចោរ

ជាតិថ្វាក្នុងសម័យរាជវង្សសៃលេន្ទ្រ ចូលឈ្លានពាន ហើយបានកៀរយកប្រជាជនមន្ត្រី និងរាជវង្សទៅកាន់ប្រទេសថ្វា។

**ក.អរិយធម៌**

អរិយធម៌ចេនឡាត្រូវពឹងផ្អែកលើឯកសារចិនរាជវង្សស្វយដែលកត់ត្រាក្នុងរជ្ជកាល**ព្រះបាទឦសានវរ្ម័ទី១** ហើយ**លោកម៉ា-តួនលិន**បានចំលងដាក់ក្នុងសៀវភៅ ការសិក្សាពីប្រជារាស្ត្រក្រៅប្រទេសចិន របស់លោកនៅសតវត្សទី១៣។

**ខ.ជីវភាពមនុស្ស**

មនុស្សនៅសម័យនោះ មាឧតូចហើយសំបុរខ្មៅ ដូចមនុស្សនគរវ្នំដែរស្រីៗភាគច្រើនសម្បុរស (នេះមកពីមានការចូលម្លប់ទេដឹង?)។ ទាំងប្រុសស្រីបួងសក់ ហើយពាក់រយ៉ាថែមទៀត។ លក្ខណៈរូបរាងកាយបែបនេះឃើញថាដូចពួកខ្មែរលើដែលរស់នៅតំបន់ខ្ពង់រាបសព្វថ្ងៃច្រើន។ ពួកអ្នកស្រុកចេនឡាមានគំនិតឆ្លាតវាងវៃ និងមានមាឌមាំមួនទៀតផង។ គេចាត់ទុកដៃស្តាំបរិសុទ្ធហើយដៃឆ្វេងមិនបរិសុទ្ធ។ រាល់ព្រឹកគេលុបលាងមុខចាក់ធ្មេញរួចអានសៀវភៅ រឺ សូត្រធម៌។ មុនពេលហូបអាហារគេតែងលុបលាងសាជាថ្មីលុះទទួលទានរួចហើយគេតែងចាក់ធ្មេញ ហើយគេសូត្រធម៌ជាថ្មីថែមទៀត។ ក្នុងម្ហូបអាហារគេចូលចិត្តប្រើ ទឹកដោះគោ ស្ករគ្រាប់ល្អិត បាយ និង Millet។ គេនិយមរាប់ញាតិខ្សែខាងម្តាយ (សិលាចារឹក)។ ការរើសគូរស្រេករវិញគឺប្រុសៗទៅដណ្តឹងស្រីៗ ឃើញថាសម័យនេះខុសពីសម័យវ្នំ។ មុនដំបូងប្រុសៗត្រូវលើកជំនូនទៅខាងស្រី បន្ទាប់មកខាងស្រីត្រូវរើសថ្ងៃមង្គលការ ដើម្បីនាំកូនស្រីទៅផ្ទះកូនប្រុស តាមរយៈមេអណ្តើកម្នាក់។ គ្រួសារទាំងសងខាងត្រូវនៅផ្ទះរហូតរយៈពេល ៨ ថ្ងៃ ហើយអុជចង្កៀងទាំងយប់ទាំងថ្ងៃ។លុះមង្គលការចប់ហើយ កូនប្រុសទទួលកេរមត៌កពីឪពុកម្តាយខ្លួន ហើយទៅរស់នៅបែកផ្ទះដោយឡែក។ ដល់ឪពុកម្តាយស្លាប់ទៅ កូនណាដែលនៅលីវនឹងទទួលបាកកេរមរតកដែលនៅសេសសល់ បើសិនជាកូនទាំងអស់នោះមានប្តីប្រពន្ធអស់ ហើយទ្រព្យសម្បត្តិទាំងនោះត្រូវយកទៅដាក់ក្នុងឃ្លាំងជាតិ។ ក្នុងពិធី

បុណ្យសពកូនទាំងអស់ត្រូវអត់បាយ ៧ ថ្ងៃ និងកោរសក់ហើយត្រូវយំស្រែកខ្លាំងៗ។ ក្រុមគ្រួសារសព ភិក្ខុ និង ភិក្ខុនីដើរដង្ហែសពដោយមានច្រៀងនិងលេងភ្លេងផង។ សពគេបូជាក្នុងបច្ឆាសង់ពីឈើក្រអូប រួចគេរើសធាតុដាក់ក្នុងកោដ្ឋមាស ឬ ប្រាក់រួចយកទៅបោះចូលក្នុងទឹក។ ពួកអ្នកក្រប្រើកោដ្ឋដីមានលាបពណ៌ផ្សេងៗ អ្នកខ្លះយកសពបោះចោលទៅក្នុងព្រៃស្មសានឲ្យសត្វស៊ី។ ទំលាប់មួយទៀតរបស់អ្នកស្រុកមួយទៀតគឺពេលចេញទៅណាមកណាមានពាក់អាវក្រោះ និងកាន់អាវុធ ហើយបើមានរឿងបន្តិចបន្តួច គេក៏ប្រយុទ្ធបង្ហូរឈាមគ្នាភ្លាម។

**គ.នយោបាយ និង រដ្ឋបាល**

ក្នុងរជ្ជកាលព្រះបាទល្បសានវម្ម៌ រាជធានីតាំងនៅល្បសានបុរហើយមានគ្រួសារ ២០០០០ គ្រួសារ។ នៅកណ្តាលក្រុងមានសាលធំមួយ ជាទីដែលព្រះរាជាទ្រង់ព្រះប្រទានសវនការនិងជួបជុំពួកមន្ត្រីសេនាបតី។ នៅខាងក្រៅរាជធានីមានក្រុងចំនួន ៣០ ទៀតក្រុងនីមួយៗ មានច្រើនពាន់គ្រួសារហើយគ្រប់គ្រងដោយអភិបាលម្នាក់។ ៣ ថ្ងៃម្តងព្រះរាជាយាងទៅសាលប្រជុំ។ មន្ត្រីជាន់ខ្ពស់មាន ៥ នាក់៖ ទី១មានងារហៅតាមចិនថា Kou-Lo-Yeou, ទី២ Siang-Kao-Ping, ទី៣ Po-Hoto-Ling ទី៤ Cho-Mo-Ling ទី៥ Jan-Lo-Leou ។ គេមិនទាន់ដឹងគោរម្យងារនេះត្រូវនឹងពាក្យខ្មែរថាម៉េចទេ។ ឯមន្ត្រីតូចតាចវិញមានចំនួនច្រើនណាស់។

នៅចំពោះមុខព្រះរាជា ពួកមន្ត្រីត្រូវធ្វើគារវកិច្ចឱនក្បាលដល់ដីបីដង។ បើស្តេចមានព្រះបន្ទូលហៅឬប្រើ ពួកមន្ត្រីត្រូវលុតជង្គង់រត់ទៅ ទៅអង្គុយដំកង់ជុំវិញព្រះរាជាដើម្បីពិភាក្សាពីកិច្ចប្រទេសជាតិ។ ចប់កិច្ចហើយគេត្រូវលុតជង្គង់សំពះសាជាថ្មីមុននឹងត្រឡប់ទៅវិញ។ ទាហានរាប់ពាន់នាក់បំពាក់អាវក្រោះកាន់លំពែងឈរយាមគ្រប់ទីកន្លែង តាំងពីជុំវិញរាជបល្លង្ករហូតដល់ទ្វារទាំងឡាយ។

ចំពោះការផ្ទេររាជសម្បត្តិគឺមានតែបុត្ររបស់អគ្គមហេសីទេ ទើបឡើងសោយរាជ្យបាន។ ដល់ថ្ងៃប្រារព្ធពិធីអភិសេកព្រះរាជាថ្មី គេកាត់ម្រាមដៃ

ច្រមុះនៃបុត្រងទៀតៗ រួចយកទៅឃុំទុកនៅកន្លែងទីទៃៗពីគ្នា ដោយមិនឲ្យកាន់តំណែងអ្វីមួយសោះឡើយ។

**ឃ.សេដ្ឋកិច្ច**

សម័យចេនឡាសេដ្ឋកិច្ចខ្មែរពឹងលើវិស័យកសិកម្មជាចម្បង ពីព្រោះទីក្រុងធំដែលរីកចម្រើនទាំងអស់សុទ្ធតែនៅក្បែរមាត់ស្ទឹងបូករួមទាំងនយោបាយទឹក ដែលមានពីអាណាចក្រវ្នំផងសេដ្ឋកិច្ចចេះតែលូតលាស់ជាលំដាប់។ ឧ.ក្រុងល្បសានបុរៈបានកសាងនៅក្បែរមាត់ស្ទឹងសែន ឯទឹកស្ទឹងត្រូវបង្ហូរចូលស្រះដែលព័ទ្ធជុំវិញក្រុង និងអាងទឹកក្នុងផ្ទៃក្រុង៖ ធ្វើដូច្នេះគេអាចមានទឹកប្រើប្រាស់គ្រប់គ្រាន់ ហើយមានលទ្ធភាពពង្រីកដីដាំដំណាំទៀតផង។ បើតាមឯកសារចិនគេដាំស្រូវ Seigle, Mil និង Gros Millet។ គេដឹងថាស្រូវប្រាកដជាមានតែដំណាំផ្សេងៗទៀតមិនដឹងថាមានឬអត់ទេ។

**ង.វប្បធម៌**

នៅក្នុងវិស័យអក្សរសាស្រ្តគេឃើញមានសិលាចារឹកជាភាសាខ្មែរបុរាណនៅអង្គរបុរីជាលើកទីមួយ។ ក្នុងវិស័យអក្សរសិល្ប៍បើតាមសិលាចារឹកវាលកន្ទួលបាននិយាយថា គេសូត្ររៀងរាល់ថ្ងៃនូវរឿងរាមាយណៈ រឿងមហាភារតៈនិងគម្ពីរបុរាណ។ ក្នុងវិស័យជំនឿសាសនាបើតាមសិលាចារឹកឃើញមានការគោរពបូជាគណៈផ្សេងៗ៖

**គណៈសិវៈ** : ជាសាសនាផ្លូវការ ព្រោះមានកសាងលិង្គព្រះឥសូរជាច្រើនដូចព្រះបាទភវវម្ម័ទី១ និងប្អូនរួមមាតាតែមួយចិត្រសេនាបានធ្វើ។ ព្រះបាទជយវម្ម័ទី១ បានយកមរណនាមរួចទៅហើយ។ យ៉ាងណាមិញសិលាចារឹកឆ្នាំ ៧១៣ និយាយថា ព្រះរាជាដែលយាងទៅកាន់សិវបុរៈ ប្រហែលជាចង់សំដៅចំពោះព្រះអង្គនេះឯង។ចំណែកមរណនាមឥន្រ្ទលោកដែលចារក្នុងសិលាចារឹក **នៅឆ្នាំ ៨០៣** ក៏ទំនងសំដៅចំពោះព្រះបាទបុស្ករាក្ស ដែលទ្រង់បានយាងទៅសោយរាជ្យនៅសម្ពុបុរនៅពេលដែលរាជបល្លង្កនៅទីនោះទំនេរ ហើយដែលព្រះអង្គប្រើកំលាំងផង។ ក្រៅពីគោរពបូជាលិង្គព្រះឥសូរនៅមានគណៈមួយទៀតដែលគោរពព្រះឥសូរដែរ គឺគណៈបាសុបត។

គណៈវិស្ណុ : មិនសូវមានគេនិយមទេ។ មានការគោរពចំពោះគណៈបញ្ចរាត្រ។

**ហរិហរៈ** : គេគោរពព្រះហរិហរៈបន្តពីសម័យអាណាចក្រវ្នំមក។ មានរូបបដិមាហរិហរៈយ៉ាងល្អវិចិត្រ ហើយមានរាងសង្ហារថែមទៀត ដូចជាហរិហរៈប្រាសាទអណ្តែត (ស្មោង-កំពង់ធំ) ជាដើម។ តែក្រោយពីនេះគេពុំឃើញ មានការគោរពហរិហរៈទៀតឡើយ។

**ពុទ្ធសាសនា** : មិនបាត់បង់ទេតែទំនងជាត្រូវសាបសូន្យបន្តិចម្តងៗជាពិសេស**នៅស.វ.ទី៧** បើផ្អែកទៅលើសក្ខីភាព របស់ពុទ្ធសាសនិកចិនឈ្មោះយីស៊ីង។ គេឃើញមានតែសិលាចារឹកមួយគត់និយាយពីព្រះភិក្ខុពីរអង្គ។ ពុទ្ធសាសនាមហាយានចាប់ផ្តើមឃើញមានគេគោរពបូជាខ្លះៗហើយ។

**ស្ថាបត្យកម្ម**: ក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទច្រើនតែសង់ពីឥដ្ឋដាច់ៗពីគ្នាឬផ្តុំគ្នាជាក្រុម។ ផ្តែនិងក្របក្លោងទ្វារគេធ្វើពីថ្មភក់។ រូបចំលាក់បដិមានៅមានជាប់លក្ខណៈឥណ្ឌានៅឡើយ តែភាគច្រើន បានបង្ហាញក្បាច់រចនាបែបខ្មែរ ហើយមានរាងសង្ហារផង (ហរិហរៈ ប្រាសាទអណ្តែត)។ ចំលាក់តុបតែង (Sculpture Decorative) មានសភាពល្អប្រណីតហើយថែមទាំងបានបន្តអានុភាពរបស់ខ្លួន រហូតដល់ក្នុងសម័យអង្គរទៀត។

**ភាសា**: ក្រៅពីភាសាសំស្ក្រឹតដែលមានប្រើតាំងពីដើមរៀងមកនេះជាលើកដំបូងដែលគេឃើញមានប្រើភាសាខ្មែរបុរាណក្នុងសិលាចារឹកៗខ្មែរដំបូងដែលមានចុះកាលកំណត់ច្បាស់គឺ **សិលាចារឹកអង្គរបុរីឆ្នាំ៦១១**។ ក្នុងផ្នែកអក្សរសិល្ប៍សិលាចារឹកវាលកន្ទេលបាននិយាយថាគេសូត្រជារៀងរាល់ថ្ងៃនូវរឿងរាមាយណ រឿងមហាភារត។

**សិលាចារឹក**: នៅសម័យចេនឡានេះយើងឃើញមានសិលាចារឹកជាច្រើននៅពាសពេញប្រទេស ដែលសរសេរជាអក្សរសំស្ក្រឹត និងជាអក្សរខ្មែរបុរាណខ្លះ ។ ខ្លឹមសារនៃសិលាចារឹកទាំងនោះច្រើនលើកឡើងអំពី កាលឧទ្ទិសដល់ព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ។

**ទំនៀមទម្លាប់**: គេនិយមរាប់អានញាតិដោយខ្សែតាមម្តាយ ក្នុងរឿងជ្រើសរើសគូស្រករ គឺពួកប្រុសៗ ទៅដណ្តឹងស្រីត្រង់នេះឃើញថា មានការរិ

វត្តប្លែកពីសម័យមុនដែលពួកស្រីៗទៅដណ្តឹងប្រុសៗ ។ មុនដំបូងខាងប្រុសត្រូវលើកជំនូនទៅខាងគ្រួសារស្រីដែលខ្លួនពេញចិត្ត បន្ទាប់មកខាងស្រីត្រូវជ្រើសរើស ថ្ងៃមង្គលដើម្បីនាំកូនស្រីទៅផ្ទះខាងប្រុសតាមរយៈមេអណ្តើកម្នាក់ ។ គ្រួសារទាំងសងខាងស្ថិតនៅក្នុងផ្ទះ អស់រយៈពេល៨ថ្ងៃ ដោយពុំមានចេញទៅណាមកណា ហើយដោយមានអុជចង្កៀងទាំងយប់ទាំងថ្ងៃ ។ លុះពិធីមង្គលការចប់សព្វគ្រប់ ហើយកូនប្រុសទទួលមតិកពីឪពុកម្តាយបង្កើតរបស់ខ្លួន ហើយបែកផ្ទះទៅនៅដោយឡែក ។ ដល់ពេលឪពុកម្តាយស្លាប់ទៅពួកកូនដែលនៅលីវអាចទទួលយកមតិកដែលសេសសល់ទាំងអស់ ប៉ុន្តែប្រសិនបើ
កូនទាំងនោះមានប្តីប្រពន្ធហើយបានទទួលមតិករួចហើយនោះ ទ្រព្យដែលនៅ សល់ត្រូវគេបញ្ជូនទៅទុកនៅឃ្លាំង ជាតិ ។

ក្នុងពិធីបុណ្យសពកូនទាំងឡាយរបស់សពត្រូវអត់បាយ៧ថ្ងៃត្រូវកោរសក់ហើយត្រូវយំស្រែកយ៉ាងខ្លាំង។ ក្រុមគ្រួសារនៃសពដោយរួមនឹងព្រះភិក្ខុនិងភិក្ខុនី បានធ្វើក្បួនដង្ហែដោយមានចម្រៀង? និងលេងភ្លេងផង។ សពគេបូជាក្នុងបច្ឆាសង់ដោយឈើក្រអូបរួចគេរើសធាតុដាក់ក្នុងកោដ្ឋមាស ឬប្រាក់ហើយយកទៅទម្លាក់ចោលក្នុងទឹក ។ ពួកអ្នកក្រគេប្រើកោដ្ឋដីមានលាបពណ៌ផ្សេងៗ ។ មានខ្លះគ្រាន់តែយកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី។ ទម្លាប់អ្នកស្រុកម្យ៉ាងទៀត គឺពេលទៅណាមកណាមានពាក់អាវក្រោះ និងកាន់អាវុធ ហើយបើកាលណាមានរឿងបន្តិចបន្តួច គេក៏ប្រយុទ្ធបង្ហូឈាមគ្នាភ្លាម។